# ព្រះរាជក្រឹត្យ

នស/រកត/០៦១៧/៤៤៤

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

## គ្រាស់បន្ទាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើត **ក្រុមប្រឹក្សាជាតិគាំពារសង្គម** សរសេរជាអក្សរកាត់ថា **ក.ជ.គ.ស.** ដើម្បីដឹកនាំ រៀបចំ និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមាសភាព និងរចនាសម្ព័ន្ធ

**មាត្រា ២ .-**

**ក.ជ.គ.ស.** មានសមាសភាពដូចតទៅ÷

| | | |
|---|---|---|
| ១- | នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធានកិត្តិយស |
| ២- | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ៣- | រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៤- | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៥- | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៦- | អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មួយរូប | អនុប្រធាន |
| ៧- | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨- | រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- | រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១០- | រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ១១- | រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១២- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មួយរូប | សមាជិក |
| ១៣- | រដ្ឋលេខាធិការក្រសួងការពារជាតិ មួយរូប | សមាជិក។ |

**ក.ជ.គ.ស.** អាចមានសមាសភាពបន្ថែមជារដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **ក.ជ.គ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៣

## តួនាទី និង ភារកិច្ចរបស់ ក.ជ.គ.ស.

**មាត្រា ៣ .-**

តួនាទី និងភារកិច្ចរបស់ **ក.ជ.គ.ស.** មានដូចខាងក្រោម÷

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម
- រៀបចំ និងបង្កើតក្របខ័ណ្ឌស្ថាប័ន យន្តការអភិបាលកិច្ច ទាំងថ្នាក់ជាតិ និងក្រោមជាតិ ដើម្បីអនុវត្តកម្មវិធីគាំពារសង្គមប្រកបដោយប្រសិទ្ធភាព
- ធ្វើសមាហរណកម្ម និងសុខដុមនីយកម្ម របបសន្តិសុខសង្គម និង/ឬកម្មវិធីជាតិជំនួយសង្គមដែលមានស្រាប់ស្របតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម
- កៀរគរធនធានហិរញ្ញវត្ថុ និងកសាងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងវិស័យគាំពារសង្គម
- តាមដាន ត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

## ជំពូកទី៤

## ការប្រព្រឹត្តទៅនៃ ក.ជ.គ.ស.

**មាត្រា ៤ .-**

ក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា ៣ **ក.ជ.គ.ស.** ត្រូវបង្កើតគណៈកម្មាធិការប្រតិបត្តិជាសេនាធិការដឹកនាំ និងសម្របសម្រួលការរៀបចំ និងការអនុវត្តគោលនយោបាយគាំពារសង្គម។ គណៈកម្មាធិការប្រតិបត្តិ អាចមានអនុគណៈកម្មាធិការ ឬក្រុមការងារបច្ចេកទេស ជាជំនួយការតាមការចាំបាច់។ គណៈកម្មាធិការប្រតិបត្តិ និងអនុគណៈកម្មាធិការ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ។ ក្រុមការងារបច្ចេកទេសរបស់ **ក.ជ.គ.ស.** ត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់ **ក.ជ.គ.ស.**។

**មាត្រា ៥ .-**

**ក.ជ.គ.ស.** មានអគ្គលេខាធិការដ្ឋានមួយសម្រាប់ជា សេនាធិការបច្ចេកទេសបម្រើការងារឲ្យក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិ ។ អគ្គលេខាធិការដ្ឋាននៃ **ក.ជ.គ.ស.** ស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ **គ.ជ.គ.ស.**។

**មាត្រា ៦ .-**

**គ.ជ.គ.ស.** មានសិទ្ធិចេញសេចក្ដីណែនាំ ឬបទបញ្ជាផ្សេងៗ តាមការចាំបាច់ពាក់ព័ន្ធនឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងប្រតិបត្តិការសន្តិសុខសង្គម អនុលោមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៧ .-**

អនុប្រធាន និងសមាជិក **គ.ជ.គ.ស.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចដើម្បីចូលរួមប្រជុំជំនួសក្នុងករណីអវត្តមាន។

ក្នុងករណីអវត្តមានរបស់ប្រធាន **គ.ជ.គ.ស.** អនុប្រធាន តាមរយៈការផ្ទេរសិទ្ធិរបស់ប្រធាន បំពេញមុខងារជាប្រធានស្ដីទី ដឹកនាំកិច្ចប្រជុំ។

**គ.ជ.គ.ស.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ដំណើរការការងារ។

**មាត្រា ៨ .-**

ប្រធាន **គ.ជ.គ.ស.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ និងសម្រេចការងារផ្សេងៗ តាមការចាំបាច់ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ។

**មាត្រា ៩ .-**

**គ.ជ.គ.ស.** គណៈកម្មាធិការប្រតិបត្តិ អនុគណៈកម្មាធិការ និងក្រុមការងារបច្ចេកទេស មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិ ចូលរួមប្រជុំដើម្បីពិគ្រោះយោបល់តាមការចាំបាច់។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ១១ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នរកត.០៦១៧.៦៩៣

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ៥០៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**